ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមន្ទីរពិសោធន៍
# គណៈវិស្វករកម្ពុជា

ឆ្នាំ ២០១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៨៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើតនិងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតនិងដាក់ឲ្យដំណើរការមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ដែលសរសេរជាអក្សរកាត់ថា ម.គ.វិ.ក. ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈវិស្វករកម្ពុជា ដោយមានអគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជាជាអង្គភាពសម្របសម្រួលក្នុងដំណើរប្រព្រឹត្តទៅរបស់ **ម.គ.វិ.ក.** នេះ។

p

**មាត្រា២ .-**

**ម.ឥ.មិ.ក.** ត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ផ្តល់ឲ្យគណៈវិស្វករកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ត្រួតពិនិត្យ វិភាគ តាមដាន និងធ្វើកោសលវិច័យ លើការប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា
- សហការបណ្តុះបណ្តាលបំប៉នវិជ្ជាជីវៈវិស្វកម្មជាក់ស្តែងដល់វិស្វករចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈវិស្វកម្មគ្រប់មុខជំនាញទាំងទ្រឹស្តីទាំងបទពិសោធ ឲ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមស្តង់ដាកំណត់ ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារពលកម្មក្នុងស្រុក តំបន់ និងអន្តរជាតិ
- បង្កលក្ខណៈងាយស្រួលដល់គណៈវិស្វករកម្ពុជា ដើម្បីធ្វើការសិក្សា វិភាគ វាយតម្លៃគុណភាពសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- តាមដានការងារអនុវត្តរបស់វិស្វករអាជីពដើម្បីធ្វើការណែនាំផ្នែកបច្ចេកទេសក្នុងការងារវិស្វកម្ម ដើម្បីធានានូវក្រមសីលធម៌វិជ្ជាជីវៈ គុណភាព សោភណភាព និងការសន្សំសំចៃ
- សហការជាមួយដៃគូអភិវឌ្ឍឬក្រុមហ៊ុនឯកជននានា ដើម្បីឲ្យ **ម.ឥ.មិ.ក.** មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវានិងអភិវឌ្ឍខ្លួន។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា៣ .-**

**ម.ឥ.មិ.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសថ្មីៗតាមសម័យនិយម លើមុខជំនាញវិស្វកម្ម ព្រមទាំងចូលរួមសហការកសាងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធវិជ្ជាជីវៈវិស្វកម្ម ដើម្បីធ្វើការផ្សព្វផ្សាយដល់វិស្វករសម្រាប់អនុវត្តទូទាំងប្រទេស
- កំណត់ពីស្តង់ដានៃគុណភាពប្រភេទសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- សហការជាមួយមន្ទីរពិសោធន៍ដែលមានស្រាប់ នៅតាមក្រសួង មន្ទីរ សហគ្រាស គ្រឹះស្ថានឧត្តម-សិក្សានានា ដើម្បីទទួលបាននូវស្តង់ដាបទដ្ឋានបច្ចេកទេសជាតិមួយសម្រាប់ផ្សព្វផ្សាយនិងអនុវត្ត
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេស កោសលវិច័យ ពិនិត្យកំហុសឆ្គងក្នុងវិស័យវិស្វកម្មដល់វិស្វករចុះបញ្ជី
- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជនដើម្បីឲ្យ **ម.ឥ.មិ.ក.** មានសមត្ថភាពពេញលក្ខណសម្បត្តិក្នុងការផ្តល់សេវា និងបណ្តុះបណ្តាល បង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្មដល់វិស្វករចុះបញ្ជី
- ទទួលកម្មសិក្សាការីអ្នកបច្ចេកទេស សម្រាប់បណ្តុះបណ្តាលឲ្យមានវិជ្ជាជីវៈជំនាញពិតប្រាកដ
- រៀបចំសារណាបច្ចេកទេស ដោយផ្អែកលើលទ្ធផលនិន្នន័យដែលទទួលបាន ក្នុងពេលបំពេញបេសកកម្ម និងតួនាទីភារកិច្ចរបស់ខ្លួន។

**មាត្រា៤ .-**

សិទ្ធិនិងការទទួលខុសត្រូវរបស់ប្រធាន **ម.គ.ទិ.ភ.** ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងលក្ខខណ្ឌ តួនាទីភារកិច្ច និងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវា។

លក្ខខណ្ឌតួនាទីភារកិច្ច និងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវាគំរូជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការគ្រប់គ្រងបុគ្គលិក

**មាត្រា៥ .-**

**ម.គ.ទិ.ភ.** ត្រូវបានដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូបដែលមានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលមានឋានៈស្មើអគ្គនាយករង។

ប្រធាន **ម.គ.ទិ.ភ.** ត្រូវទទួលខុសត្រូវក្នុងការរៀបចំដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

ប្រធាន **ម.គ.ទិ.ភ.** ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនិងដំណើរការការងារជូនប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

បុគ្គលិកបម្រើការងារនៅ **ម.គ.ទិ.ភ.** ជាមន្ត្រីមុខងារសាធារណៈឬមន្ត្រីជាប់កិច្ចសន្យារបស់គណៈវិស្វករកម្ពុជា។

**មាត្រា៦ .-**

**ម.គ.ទិ.ភ.** ត្រូវបានអនុញ្ញាតឱ្យប្រើត្រាដោយឡែក។

## ជំពូកទី៤
## រចនាសម្ព័ន្ធ

**មាត្រា៧ .-**

**ម.គ.ទិ.ភ.** មានបីផ្នែក តាមរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកបច្ចេកទេស
- ផ្នែកសហប្រតិបត្តិការនិងផ្តល់សេវា។

ផ្នែកនីមួយៗត្រូវដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។ ការកំណត់តួនាទីភារកិច្ចនិងការងារទទួលខុសត្រូវរបស់ប្រធានផ្នែកនីមួយៗ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **ម.គ.ទិ.ភ.**។

**មាត្រា៨ .-**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ចាត់ចែង ចរាចរណ៍និងគ្រប់គ្រងឯកសាររដ្ឋបាល
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារ

p

- គ្រប់គ្រងបុគ្គលិក រៀបចំការងារបៀវត្សរ៍ពេលកម្ម ប្រាក់កម្រៃ របបឧបត្ថម្ភ ឬប្រាក់លើកទឹកចិត្ត ដល់បុគ្គលិកក្របខ័ណ្ឌមុខងារសាធារណៈនិងបុគ្គលិកជាប់កិច្ចសន្យា
- រៀបចំ តាក់តែងលិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាលនានា និងធ្វើកំណត់ហេតុប្រជុំ
- ធ្វើរបាយការណ៍ការងារនិងកំណត់ហេតុផ្សេងៗរបស់ថ្នាក់ដឹកនាំ
- ធ្វើរបាយការណ៍សរុបលទ្ធផលនិងសកម្មភាពការងាររបស់ **ម.គ.ខ.ក.** ជាប្រចាំ និងធ្វើរបាយការណ៍បូកសរុបការងារប្រចាំខែ ឆមាស និងប្រចាំឆ្នាំ
- ប្រមូលទិន្នន័យស្តីពីសកម្មភាពការងារ និងលើកគម្រោងថវិកាសម្រាប់ដំណើរការ **ម.គ.ខ.ក.**
- ផ្គត់ផ្គង់និងគ្រប់គ្រងមូលដ្ឋានសម្ភារៈបរិក្ខារ **ម.គ.ខ.ក.**
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិ សម្ភារៈ និងបញ្ជីសារពើភណ្ឌ។

**មាត្រា៩ .-**

ផ្នែកបច្ចេកទេស មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូល ពិនិត្យ វិភាគ និងចងក្រងទិន្នន័យលទ្ធផលការងាររបស់ **ម.គ.ខ.ក.** កំណត់ស្តង់ដាបទដ្ឋានបច្ចេកទេសមួយ ដើម្បីធ្វើការផ្សព្វផ្សាយនិងអនុវត្តទូទាំងប្រទេស
- វិភាគនិងកំណត់ស្តង់ដាគុណភាពនៃប្រភេទ សម្ភារៈបរិក្ខារ សម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- ផ្តល់យោបល់បច្ចេកទេសលើការអនុវត្តគម្រោងវិស្វកម្មក្នុងករណីមានភាពមិនប្រក្រតី
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេសដល់វិស្វករអាជីព ជៀសវាងនូវកំហុសឆ្គងក្នុងការអនុវត្តការងារវិស្វកម្ម
- ប្រមូលផ្តុំនិងចងក្រងនូវទិន្នន័យដែលទទួលបាន ក្នុងពេលបំពេញតួនាទីភារកិច្ចរបស់ខ្លួន
- លើកគម្រោងនៃតម្រូវការនិងការថែទាំសម្ភារៈបរិក្ខារបច្ចេកទេសរបស់ **ម.គ.ខ.ក.**។

**មាត្រា១០ .-**

ផ្នែកសហប្រតិបត្តិការនិងផ្តល់សេវាមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជននានាក្នុងការអភិវឌ្ឍ និងផ្តល់សេវារបស់ **ម.គ.ខ.ក.**
- សហការជាមួយផ្នែកអប់រំនិងបណ្តុះបណ្តាលនៃអគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា និងដៃគូអភិវឌ្ឍ រៀបចំផែនការសម្រាប់បណ្តុះបណ្តាល បង្ហាត់បង្រៀនបច្ចេកទេស បង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្មដល់វិស្វករចុះបញ្ជី។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១១ .-**

ប្រភពធនធានថវិការបស់ **ម.គ.ខ.ក.**៖

- ថវិកាជាតិដែលជាឧបសម្ព័ន្ធនៃថវិការបស់គណៈវិស្វករកម្ពុជា
- ថវិកាដែលបានមកពីការបែងចែកកម្រៃសេវា
- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងពីប្រភពផ្សេងៗទៀត។

p

**មាត្រា១២ .-**

ការកំណត់ថ្លៃសេវានិងការបែងចែកកម្រៃសេវាជាមួយដៃគូអភិវឌ្ឍឬក្រុមហ៊ុនឯកជននានា ត្រូវធ្វើឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា អគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ